Disability Rights California
*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# សន្លឹកព័ត៌មានពិតអំពីការងារមុខរបរផ្ទាល់ខ្លួន

***ឯកសារបោះពុម្ពផ្សាយប្រចាំខែកុម្ភៈ ឆ្នាំ 2014 លេខ #5454.06 - Cambodian***

ព័ត៌មានក្នុងសន្លឹងព័ត៌មានពិតនេះ ត្រូវបានដកចេញពីឯកសារការធ្វើឲ្យការប្រកបមុខរបរផ្ទាល់ខ្លួនមានដំណើរការសម្រាប់ជនមានពិការភាព (Making Self- employment Work for People with Disabilities) (Griffin & Hammis, 2003) ។

## តើអ្វីជាមុខរបរផ្ទាល់ខ្លួន?

ការប្រកបមុខរបរផ្ទាល់ខ្លួន ត្រូវបានត្រូវបានបង្កើតឡើងដោយមានជំនឿថា មនុស្សមានភាពខ្លាំង មានចំណាប់អារម្មណ៍ មានចំណង់ចំណូលចិត្ត និងមានសមត្ថភាពពីកំណើត ដើម្បីបំពេញការងារប្រកបដោយសមត្ថភាព នៅពេលទទួលបានជម្រើស ការគោរព ក្ដីសង្ឃឹម និងឱកាស ។

## តើអ្វីខ្លះជាអត្ថប្រយោជន៍នៃការប្រកបមុខរបរផ្ទាល់ខ្លួន?

- សេដ្ឋកិច្ចសហរដ្ឋអាមេរិក មានលក្ខណៈជួយឲ្យការប្រកបមុខរបរផ្ទាល់ខ្លួនរបស់ពលរដ្ឋម្នាក់ៗ មានការលូតលាស់ខ្លាំង ។

- ការប្រកបមុខរបរផ្ទាល់ខ្លួន ផ្ដល់ជូនអ្នកទទួលជំនួយពីសន្តិសង្គម នូវជំនួយហិរញ្ញវត្ថុ ក្នុងអំឡុងដំណាក់កាលចាប់ផ្ដើមនៃមុខរបរ ។

- អ្នកដែលមានមុខរបរខ្លួនឯង ដែលមានពិការភាព អាចមានឱកាសទទួលបានផនធាន នៃទុនជាជម្រើស ដើម្បីកសាងមុខរបររបស់ខ្លួន ។

- ការប្រកបមុខរបរផ្ទាល់ខ្លួន អាចសាកសមចំពោះមនុស្សដែលមានពិការភាពធ្ងន់ធ្ងរ ។

- ការប្រកបមុខរបរផ្ទាល់ខ្លួន អាចឲ្យបុគ្គលនោះរៀបចំម៉ោងពេលធ្វើការដោយអនុលោមទៅតាមផលិតភាព រោគសញ្ញាពិការភាព និងគោលបំណងរបស់ខ្លួន ។

## តើខ្ញុំអាចមានមុខរបរផ្ទាល់ខ្លួនប្រភេទណាខ្លះ?

- កម្មសិទ្ធិទោល – ម្ចាស់ និងអ្នកចាត់ចែងមុខរបរ គឺជាមនុស្សតែមួយ ។
- ភាពជាដៃគូ – ជាមុខរបរដែលមានម្ចាស់ច្រើនជាងមួយនាក់ ដែលផលចំណេញ ឬកំហាតទាំងអស់ ត្រូវបែងចែកក្នុងចំណោមដៃគូទាំងអស់ ។
- ក្រុមហ៊ុនទទួលខុសត្រូវមានកំណត់ (LLC, Limited Liability Company) – ជាប្រភេទដៃគូរកស៊ី ដែលអនុញ្ញាតឲ្យមានការកាត់បន្ថយចំពោះការទទួលខុសត្រូវបំណុលរបស់ម្ចាស់ ចំពោះសាជីវកម្ម ហើយការបង្កើតការរកស៊ីក្នុងភាពជាដៃគូបែបនេះ បានទទួលអត្ថប្រយោជន៍ផ្នែកការបង់ពន្ធ ។
- សាជីវកម្ម – ជាទូទៅ ជាក្រុមហ៊ុនដែលមានបុគ្គលិក ថ្លៃមេធាវី និងថ្លៃអាជ្ញាប័ណ្ណ ។

## តើខ្ញុំអាចមានមុខរបរផ្ទាល់ខ្លួន ហើយនៅទទួលបានអត្ថប្រយោជន៍សន្តិសុខសង្គមទៀតដែរឬទេ?

ការលើកទឹកចិត្តសន្តិសុខសង្គមដើម្បីការងារ អាចយកមកប្រើ ដើម្បីជួយអ្នកក្នុងការសម្រេចបានគោលបំណងការបង្កើតមុខរបរផ្ទាល់ខ្លួនរបស់អ្នក ។ វាជាប្រការសំខាន់ដែលអ្នកត្រូវមានផែនការទទួលជំនួយ ដើម្បីជាប្រយោជន៍ និងអាចយល់បានថាតើការលើកទឹកចិត្តសន្តិសុខសង្គមដើម្បីការងារ អាចជួយអ្នកបានយ៉ាងដូចម្តេច ។

## តើខ្ញុំអាចទទួលបានជំនួយពីណា?

នាយកដ្ឋានស្តារនីតិសម្បទា (DOR, Department of Rehabilitation) ៖ http://www.oal.ca.gov

មជ្ឈមណ្ឌលការងារអាមេរិកាំង (American Job Centers) ៖ https://www.edd.ca.gov/jobs.htm

បណ្តាញការងារ (EN, Employment Network) ៖ http://www.yourtickettowork.com

ផែនការលើកទឹកចិត្ត និងគម្រោងជំនួយដើម្បីការងារ (WIPA, Work Incentive Planning and Assistance Projects) ៖ https://www.ssa.gov/work/WIPA.html

ការការពារ និងការតស៊ូមតិដើម្បីអ្នកទទួលជំនួយពីសន្តិសុខសង្គម (PABSS, Protection and Advocacy for Beneficiaries of Social Security)៖ http://www.disabilityrightsca.org ឬហៅទូរស័ព្ទមកលេខ 800-776-5746

(SSA, Social Security Administration) បានពិនិត្យឡើងវិញនូវឯកសារនេះ ដើម្បីបញ្ជាក់តែពីភាពត្រឹមត្រូវប៉ុណ្ណោះ តែទោះជាយ៉ាងណាក៏ដោយក៏ឯកសារនេះ មិនអាចចាត់ទុកជាឯកសារផ្លូវការរបស់ SSA ដែរ។

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html*